**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 07 PR-21/EoJ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២១

**ជប៉ុនផ្តល់ ៧៥៤,៣២១ ដុល្លារអាមេរិក**
**សម្រាប់ការរៀបចំវគ្គសិក្សាអប់រំកាយនៅថ្នាក់សាកលវិទ្យាល័យរយៈពេល៤ឆ្នាំ និង**
**សម្រាប់ការគាំទ្រដល់ការធ្វើកសិកម្មកិច្ចសន្យាស្វាយចន្ទីសរីរាង្គតាមរយៈសហករណ៍កសិកម្ម**

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៧៥៤,៣២១ ដុល្លារអាមេរិក ដល់អង្គភាពទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងអង្គភាពទទួលជំនួយទាំងពីរ សម្រាប់អនុវត្តគម្រោងដូចតទៅៈ

**១. គម្រោងស្តីពីការរៀបចំវគ្គសិក្សាអប់រំកាយនៅថ្នាក់សាកលវិទ្យាល័យរយៈពេល៤ឆ្នាំ នៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (ឆ្នាំទី២) (ថវិកាជំនួយ ៣៧១,៤៧៩ ដុល្លារអាមេរិក)**

**អង្គភាពទទួលជំនួយៈ អង្គការក្រៅរដ្ឋាភិបាល Hearts of Gold**

អង្គការ Hearts of Gold នឹងជួយគាំទ្រវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដើម្បីរៀបចំវគ្គសិក្សាអប់រំកាយ នៅថ្នាក់សាកលវិទ្យាល័យរយៈពេល៤ឆ្នាំ តាមរយៈការកែលម្អកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ និងការតម្លើងឧបករណ៍សម្រាប់ការអប់រំកាយ។ តាមរយៈគម្រោងនេះ បុគ្គលិកប្រមាណ ៦៥នាក់ និងគរុសិស្សប្រមាណ ៣០០នាក់ នៅក្នុងវិទ្យាស្ថាននេះ នឹងអាចទទួលបានបរិយាកាសរៀនសូត្រល្អប្រសើរសម្រាប់ការអប់រំកាយ។ ជាមួយគ្នានេះផងដែរ យើងរំពឹងថានិស្សិតជាង ៩៣០,០០០នាក់ នៅក្នុងប្រទេសកម្ពុជា នឹងទទួលបានការអប់រំកាយប្រកបដោយប្រសិទ្ធភាពជាងមុន។

**២.ការគាំទ្រដល់ការធ្វើកសិកម្មកិច្ចសន្យាស្វាយចន្ទីសរីរាង្គតាមរយៈសហករណ៍កសិកម្ម (ឆ្នាំទី៣) (ថវិកាចំនួន ៣៨២,៨៤២ ដុល្លារអាមេរិក)**

**អង្គភាពទទួលជំនួយៈ ក្រុមអ្នកស្ម័គ្រចិត្តអន្តរជាតិយ៉ាម៉ាហ្គាតា (IVY)**

នៅក្នុងគម្រោងនេះ IVY នឹងជម្រុញការដាំដុះគ្រាប់ស្វាយចន្ទីសរីរាង្គ និងការធ្វើទីផ្សារសហប្រតិបត្តិការក្នុងចំណោមកសិករនៅខេត្តព្រះវិហារដើម្បីបង្កើនប្រាក់ចំណូល និងលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។ នៅក្នុងឆ្នាំចុងក្រោយនៃគម្រោងដែលមានរយៈពេល ៣ឆ្នាំនេះ សហករណ៍កសិកម្មថ្មីចំនួន៣បន្ថែម ក្រៅពីសហករណ៍កសិកម្មកំពុងដំណើរការចំនួន១០ មានគោលបំណងទទួលបានវិញ្ញាបនប័ត្រសរីរាង្គ ហើយប្រព័ន្ធត្រួតពិនិត្យដំណើរការផលិតកម្មយូរអង្វែង នឹងត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឱ្យសហករណ៍កសិកម្មនីមួយៗក្លាយជាអង្គភាពប្រតិបត្តិនៃទីផ្សារសហប្រតិបត្តិការ និងការគ្រប់គ្រងដំណើរការផលិតកម្ម បន្ទាប់ពីការបញ្ចប់គម្រោង។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៤២លានដុល្លារអាមេរិក ដល់គម្រោងចំនួន១៣៣ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ័៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីម៉ែល៖ eco.jpn@.pp.mofa.go.jp
គេហទំព័រ៖ http://www.kh.emb-japan.go.jp